អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង
# សន្និសីទសារព័ត៌មានទាក់ទងនឹង
# សវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១

ផ្នែកកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មានកិត្តិយសសូមអញ្ជើញតំណាងប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិ ចូលរួមក្នុងសន្និសីទសារព័ត៌មានមួយដែលរៀបចំឡើងមុនការចាប់ផ្តើមសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ ប្រឆាំងនឹងខៀវ សំផន និង នួន ជា។ សន្និសីទកាសែតនេះនឹងប្រព្រឹត្តទៅនៅ***ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៥ ពីម៉ោង ១០ ព្រឹក ដល់ម៉ោង ១១ព្រឹក នៅសណ្ឋាគារភ្នំពេញ*** ស្ថិតតាមបណ្តោយមហាវិថីព្រះមុនីវង្ស។ សន្និសីទនេះនឹងមានការបកប្រែជាភាសាខ្មែរ និងអង់គ្លេស។

សវនាការលើកទី១ លើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ នឹងប្រព្រឹត្តទៅនៅថ្ងៃទី២ ៣ ៦ និងទី៧ ខែកក្កដា ឆ្នាំ ២០១៥។ សំណុំរឿង០០២/០១ គឺជាការជំនុំជម្រះលើកទីមួយនៃការជំនុំជម្រះយ៉ាងតិចពីរប្រឆាំងនឹង ខៀវ សំផន អតីតប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។ បទចោទនៅក្នុងសំណុំរឿង ០០២/០១ គឺផ្តោតលើបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលរងការចោទប្រកាន់ក្នុងអំឡុងពេលជម្លៀសនៅទីក្រុងភ្នំពេញ ក្នុងខែមេសា ឆ្នាំ១៩៧៥ និងការផ្លាស់ទីដោយបង្ខំបន្តបន្ទាប់ពីតំបន់ដទៃទៀត រួមទាំងការកាប់សម្លាប់ដែលរងការចោទប្រកាន់នៅទួលពោធិ៍ជ្រៃ ក្នុងខេត្តពោធិ៍សាត់។ នៅថ្ងៃទី ៧ ខែ សីហា ២០១៤ អង្គជំនុំជម្រះសាលាដំបូង រកឃើញថា ជនជាប់ចោទមានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារជនជាប់ចោទទាំងពីរអស់មួយជីវិត។ នួន ជា និង ខៀវ សំផន បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយម្នាក់ៗបានលើកទឡ្ហីករណ៍បណ្តឹងសាទុក្ខចំនួន ២២៣ និង ១៤៨ រៀងៗខ្លួន។ បន្ថែមលើនេះ សហព្រះរាជអាជ្ញា បានដាក់បណ្តឹងសាទុក្ខ ដោយកម្រិតត្រឹមតែស្វែងរកដំណោះស្រាយដែលប្រកាសដោយអង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងភាពអាចអនុវត្តបាននូវទម្រង់ពង្រីកបន្ថែមនៃសហឧក្រិដ្ឋកម្មរួម ដែលហៅថា “សហឧក្រិដ្ឋកម្មរួមទម្រង់ទី III” (JCE III) នៅចំពោះមុខ អ.វ.ត.ក។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ 0២៣
សារអេឡិកត្រូនិក: olsenl@un.org